ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខៈ...១៨៨.....កប /ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០០៧

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងលិខិតលេខ ៤៣៧ មស.គ្ររ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ពិនិត្យឃើញការចាំបាច់របស់អគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## សម្រេច

**ប្រការ ១ :** បង្កើតលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានឋានៈសម្ព័ន្ធស្មើនឹងការិយាល័យនៅថ្នាក់កណ្តាល ។ លេខាធិការដ្ឋាននេះមានភារកិច្ចដូចតទៅ:

- សម្របសម្រួលរាល់ឯកសារ លិខិតចេញ-ចូល របស់អគ្គនាយកដ្ឋាន
- សម្របសម្រួលរាល់កិច្ចការរបស់អគ្គនាយកដ្ឋាន ជាមួយទីស្តីការក្រសួង នាយកដ្ឋាននានាក្រោមចំណុះក្រសួង មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត-ក្រុង ក្រសួង-ស្ថាប័នរដ្ឋាភិបាល អង្គការជាតិ-អន្តរជាតិ និងដៃគូសង្គមនានា

- គ្រប់គ្រង និងចរាចររាល់ឯកសាររដ្ឋបាលផ្សេងៗរបស់អគ្គនាយកដ្ឋាន
- រៀបចំទុកដាក់ ថែរក្សា និងគ្រប់គ្រងរាល់ឯកសារ លិខិតរបស់អគ្គនាយកដ្ឋាន
- ថែរក្សា គ្រប់គ្រងសម្ភារៈ បរិក្ខារ ចលនទ្រព្យ និងអចលនទ្រព្យនានារបស់អគ្គនាយកដ្ឋាន
- ណែនាំរបៀបរបបការងាររដ្ឋបាលរបស់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋាន
- រៀបចំអង្គប្រជុំ និងធ្វើរបាយការណ៍ ឬកំណត់ហេតុអង្គប្រជុំរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំរបស់អគ្គនាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗតាមការណែនាំរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន ។

**ប្រការ ២ :** លេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

**ប្រការ ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ :** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី** ៣

**ចំរុង សុត**

**<u>ចម្លងជូន</u> :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ